**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០៧២......ន.គ.ស .សរ.ន.ណ

ថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំលឹកអំពីការអនុវត្តកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ឱ្យរងសវនកម្មឯករាជ្យ និង ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច មកនិយ័តករគណនេយ្យនិងសវនកម្ម

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម អនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងប្រកាសលេខ៥៦៣ សហវ.ប្រក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ **និយ័តករគណនេយ្យនិងសវនកម្ម** នៃ**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** សូមជម្រាបជូន អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាម្ចាស់សហគ្រាសទាំងអស់ មេត្តាជ្រាបថា៖ សហគ្រាសទាំងឡាយណាដែលស្ថិតនៅក្នុង**ចំណុច ១ ដល់ ៤** ខាងក្រោម **មានកាតព្វកិច្ចត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ឱ្យរងសវនកម្មឯករាជ្យជាកំហិត**៖

១. សហគ្រាសសាធារណៈ

២. សហគ្រាសទទួលខុសត្រូវជាសាធារណៈ

៣. គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៤. សហគ្រាសដែលមិនស្ថិតក្នុងចំណុច ១, ២ និង ៣ ខាងលើ ប៉ុន្តែបានបំពេញលក្ខណៈវិនិច្ឆ័យទាំង២ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យចំនួន៣ ខាងក្រោម ត្រូវមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ៖

**លក្ខណៈវិនិច្ឆ័យ១៖** មានទឹកប្រាក់ផលរបរប្រចាំការិយបរិច្ឆេទគណនេយ្យចាប់ពី ៤.០០០.០០០.០០០(បួនប៊ីលាន) រៀល ឡើងទៅ។

**លក្ខណៈវិនិច្ឆ័យ២៖** មានទ្រព្យសកម្មសរុបចាប់ពី ៣.០០០.០០០.០០០ (បីប៊ីលាន)រៀល ឡើងទៅ គិតត្រឹមថ្ងៃបិទការិយបរិច្ឆេទគណនេយ្យ។

**លក្ខណៈវិនិច្ឆ័យ៣៖** មានចំនួនកម្មករនិយោជិតបម្រើការងារចាប់ពី១០០(មួយរយ)នាក់ ឡើងទៅ ដោយយោងទៅតាមចំនួនកម្មករនិយោជិតមធ្យមភាគ ដែលមានក្នុងឆ្នាំ។

សហគ្រាសអាចជ្រើសរើសក្រុមហ៊ុនសវនកម្មឯករាជ្យណាមួយដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មនៅមានសុពលភាព ដែលផ្តល់ដោយ **ន.គ.ស.**។

សហគ្រាសត្រូវបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មឯករាជ្យ មិនឱ្យហួសរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យ និងត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួចមក **ន.គ.ស.** មិនឱ្យហួសរយៈពេល៦(ប្រាំមួយ)ខែ និង១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ: ០២៣ ៨៨២ ១១១
Phone: 023 882 111

សហគ្រាសត្រូវប្រើប្រព័ន្ធអនឡាញ (E-filing system) របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មមក **ន.គ.ស.**។ បែបបទ និងនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញ (E-filing system) ព្រមទាំងវិធានអនុវត្ត ដែលនឹងត្រូវកំណត់ដោយ **ន.គ.ស.**។

ការមិនបានអនុវត្តកាតព្វកិច្ចនេះ សហគ្រាស នឹងរងទោសទណ្ឌស្របតាម**អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម**។ សហគ្រាសដែលមិនបានបំពេញកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ សម្រាប់ការិយបរិច្ឆេទគណនេយ្យឆ្នាំ២០២០ មក **ន.គ.ស.** និងមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មមក **ន.គ.ស.** ត្រូវរងពិន័យអន្តរការណ៍ ដូចបានកំណត់នៅក្នុង**ចំណុច ឃ** និង **ង នៃមាត្រា៤** ឬ **មាត្រា៥** នៃអនុក្រឹត្យ លេខ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម និងមិនមានការលើកលែង។

**សហគ្រាសដែលនៅតែបន្តមិនអនុវត្តកាតព្វកិច្ចនេះសម្រាប់ការិយបរិច្ឆេទគណនេយ្យឆ្នាំ ២០២១ និងការិយបរិច្ឆេទឆ្នាំបន្តបន្ទាប់ ត្រូវបានចាត់ទុកជា "ករណីមិនរាងចាល" និងត្រូវរងនូវពិន័យអន្តរការណ៍ ដូចបានកំណត់នៅក្នុងមាត្រា១១នៃអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម**។

វេទិកាស្ដីពីនីតិវិធីនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មមក **ន.គ.ស.** នឹងធ្វើឡើងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ៨:៣០នាទីព្រឹក តាមប្រព័ន្ធអនឡាញ (Zoom)។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈលេខទូរស័ព្ទ និងតេឡេក្រាម÷ ០៧០ ៩២ ៩២ ៣៧ ឬ ០១៦ ៥៩ ៨៣ ៨៦ ឬ០៧៧ ៩៦ ៨៣ ៩៦ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាម្ចាស់សហគ្រាស មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ប៊ូ ថារិន**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់ និយ័តករគណនេយ្យនិងសវនកម្ម**